# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Feb-2013, 14:19
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៩២ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម យូ ឧត្តរា
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS

លោក គង់ សំអុន
លោកស្រី Anta GUISSE
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១- នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីកាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ ក្រុមមេធាវីការពារក្តីរបស់ អៀង សារី និងដើមបណ្តឹងរដ្ឋប្បវេណី បានពិភាក្សាលើបញ្ហាស្តីពីទម្ងន់ដែលត្រូវដាក់ទៅលើសេចក្តីថ្លែងនានាដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនផ្តល់សក្ខីកម្មនៅក្រោមសម្បថ។ ក្រុមមេធាវីការពារក្តីរបស់ អៀង សារី បានទទួលស្គាល់នូវ "សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលថាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិផ្តល់នូវចម្លើយ មិនចាំបាច់ត្រូវស្បថ។ ដូច្នេះ អង្គជំនុំជម្រះមានសិទ្ធិពិចារណាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងភស្តុតាងទាំងអស់ដទៃទៀត ហើយមានសិទ្ធិផ្តល់នូវទម្ងន់សមស្របចំពោះសក្ខីកម្មដែលគេបានផ្តល់"[1]។ លោកស្រីចៅក្រម Cartwright បានកត់សម្គាល់ថា៖

> *ចំពោះការពិភាក្សាអំពីបញ្ហាថាតើដើមបណ្តឹងរដ្ឋប្បវេណីត្រូវស្បថ ឬមិនស្បថនោះ ព្រមទាំងផលវិបាកនៃការស្បថ ឬមិនស្បថនោះ យើងបានពិភាក្សាជាច្រើនដងរួចមកហើយ។ ហើយអង្គជំនុំជម្រះបានដឹងច្បាស់លាស់អំពីការទទួលខុសត្រូវដែលបានធ្វើឡើង។ ហើយយើងមិនចង់ឲ្យមានការលើកឡើងនូវទឡ្ហីករណ៍ដដែលៗ ឬក៏លើកឡើងជាញឹកញាប់បែបនេះនោះទេ*[2]។

២- ដោយយកចិត្តទុកដាក់ទៅលើការរំលឹករបស់លោកស្រីចៅក្រម Cartwright សហព្រះរាជអាជ្ញាដាក់ជូនដោយគោរពនូវសេចក្តីសង្កេតសង្ខេប ដែលពាក់ព័ន្ធទៅនឹងទម្ងន់ដែលត្រូវផ្តល់ទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយមានក្តីសង្ឃឹម និងជំនឿមួយដែលថា ព័ត៌មានដែលបានផ្តល់ជូននៅក្នុងនេះ គឺហួសពីការពិភាក្សាពីពេលមុនៗ និងជួយផ្តល់ខ្លឹមសារដល់អង្គជំនុំជម្រះបានច្រើនជាង។

៣- ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនធំ ត្រូវបានជ្រើសរើសដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីឲ្យមកផ្តល់សក្ខីកម្មជាសំខាន់នៅក្នុងផ្នែកការជម្លៀសប្រជាជនដោយបង្ខំ នៃសំណុំរឿង ០០២/០១[3]។ នៅក្នុងផ្នែកនេះនៃសវនាការ ដើមបណ្តឹងរដ្ឋប្បវេណីនឹងផ្តល់ជូននូវភស្តុតាងសំខាន់ៗដែលនឹងមានសារៈសំខាន់នៅក្នុងការបង្ហាញអំពីឧក្រិដ្ឋកម្មនៃការជម្លៀសប្រជាជនដោយបង្ខំ និងអំពីបរិបទដែលឧក្រិដ្ឋកម្មទាំង

---

[1] ពង្រាងប្រតិចារឹក, ២៤ មករា ២០១៣, ទំព័រទី ៧៣។

[2] ពង្រាងប្រតិចារឹក, ២៤ មករា ២០១៣, ទំព័រទី ៧៥។

[3] **E236/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការបញ្ជាក់ជាបឋមអំពីបុគ្គលដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងអំឡុងសវនាការលើចំណុចអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងសំណុំរឿង ០០២/០១, ២ តុលា ២០១២។

នោះត្រូវបានប្រព្រឹត្តឡើង។ សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់នូវសេចក្ដីបន្ថែមដ៏សំខាន់មួយទៅលើភ័ស្តុតាងផ្សេងៗទៀតដែលបានបង្ហាញនៅក្នុងអំឡុងពេលនៃសវនាការ។

៤- អ.វ.ត.ក បានធ្វើតាមបែបបទច្បាប់ស៊ីវិល ហើយម្យ៉ាងទៀត បានធ្វើឲ្យខុសគ្នារវាង សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ជនជាប់ចោទ និងសាច់ញាតិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬជនជាប់ចោទ។ ដូចជាភាគីដទៃទៀតនៃកិច្ចដំណើរការនីតិវិធីដែរ គេមិនតម្រូវឲ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការផ្ដល់សក្ខីកម្មនៅក្រោមសម្បថទេ[4]។ ដើមបណ្ដឹងរដ្ឋប្បវេណីអាចនឹងធ្វើសេចក្ដីថ្លែងនានាជូនទៅតុលាការ ហើយភាគីនានា ដោយមានការអនុញ្ញាតពីលោកប្រធានសវនាការ អាចសួរអំពីសេចក្ដីថ្លែងទាំងនោះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងពេលនៃកិច្ចដំណើរការនីតិវិធីបាន[5]។

៥- អង្គជំនុំជម្រះសាលាដំបូង ធ្លាប់បានថ្លែងពីមុនថា សក្ខីកម្មដែលមិនបានធ្វើសម្បថ ដែលធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជា ជនជាប់ចោទដែរ គឺជាភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ[6]។ សហព្រះរាជអាជ្ញាជូនសេចក្ដីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការវាយតម្លៃទៅលើទម្ងន់ និងតម្លៃជាភរវនីយភាពនៃសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្រោមបទដ្ឋានតែមួយដូចគ្នានឹងសក្ខីកម្មដែលបានផ្ដល់ដោយសាក្សីដូច្នោះដែរ។

## II. ប្រវត្តិនីតិវិធី

៦- នៅក្នុងសំណុំរឿង ០០១ មានដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ២២ (ម្ភៃពីរ) នាក់ ដែលបានផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[7]។ ដោយអនុលោមតាមវិធានផ្ទៃក្នុងនៃ អ.វ.ត.ក គឺមិនមានដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់ ក្នុងចំណោមដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះ បានផ្ដល់សក្ខីកម្មនៅក្រោម

---

[4] វិធាន២៣(៤) នៃវិធានផ្ទៃក្នុង (“ដើមបណ្ដឹងរដ្ឋប្បវេណី មិនត្រូវបានគេសួរដូចជាសាក្សីធម្មតាក្នុងសំណុំរឿងតែមួយនេះបានទេ ហើយស្រប តាមវិធាន ៦២ ដែលទាក់ទងនឹងដីកាចាត់ឲ្យស៊ើបសួរជំនួស អាចត្រូវបានគេស្ដាប់ចម្លើយតែប៉ុណ្ណោះ ដោយស្ថិតក្រោមលក្ខខណ្ឌដូចគ្នាទៅនឹងជនត្រូវចោទ ឬ ជនជាប់ចោទដែរ”)។ សូមអានផងដែរ វិធាន ២៤(២) នៃវិធានផ្ទៃក្នុង ដែលចែងពីសមាជិកគ្រួសារជិតដិតរបស់ជនជាប់ចោទ ជនត្រូវចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី ដែលឆ្លើយដោយមិនចាំបាច់ធ្វើសម្បថ។

[5] វិធាន ៩១ នៃវិធានផ្ទៃក្នុង។

[6] **E188** សាលក្រម, ២៦ កក្កដា ២០១០, កថាខណ្ឌទី ៥១ (“ចម្លើយតបរបស់ជនជាប់ចោទបង្កើតបានជាភ័ស្តុតាង”) និង កថាខណ្ឌទី ៥២ (“ទោះជាយ៉ាងណាក៏ដោយ បុគ្គលទាំងនោះ [ដើមបណ្ដឹងរដ្ឋប្បវេណី] អាចផ្ដល់សក្ខីកម្ម និងដាក់សេចក្ដីថ្លែងរបស់គេនៅចំពោះមុខអង្គជំនុំជម្រះ និងវាយតម្លៃជាភ័ស្តុតាង នៅពេលមានភាពពាក់ព័ន្ធ និងមានភរវនីយភាព”)។

[7] **E188** *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌទី ៥៤។

សម្បថនោះឡើយ[8]។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការវាយតម្លៃទៅលើសេចក្តីថ្លែងនានារបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ថាជាភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ហើយបានធ្វើការពិចារណាលើសក្ខីកម្មនោះ នៅក្នុងការឈានទៅដល់សេចក្តីវិនិច្ឆ័យរបស់ខ្លួន[9]។

៧- កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីរបស់ អៀង សារី បានដាក់ញត្តិមួយស្នើសុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការផ្តល់សក្ខីកម្មនៅក្រោមសម្បថ កាលណាត្រូវបានជ្រើសរើសឲ្យមកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងបញ្ហាអង្គហេតុសំខាន់ៗ[10]។ ញត្តិនេះសំអាងថា សេចក្តីថ្លែងណាមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានប្រើប្រាស់ តែនៅក្នុងការកំណត់ពីការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនោះលើបញ្ហាសំណងប៉ុណ្ណោះ[11] ហើយបើគេកោះហៅដើមបណ្តឹងរដ្ឋប្បវេណីរូបណាមួយឲ្យមកផ្តល់សក្ខីកម្មលើ "បញ្ហានានាពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌ" នោះគាត់ត្រូវតែផ្តល់សក្ខីកម្មនៅក្រោមសម្បថ[12]។

៨- សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សេចក្តីសង្កេតមួយអំពីញត្តិរបស់ អៀង សារី ដោយបានសង្កត់ធ្ងន់ថា ដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីស្មើគ្នាទាំងស្រុងនៅក្នុងកិច្ចដំណើរការនីតិវិធី និងតាមវិធាន អាចនឹងផ្តល់ភ័ស្តុតាងនៅក្រោមលក្ខខណ្ឌតែមួយដូចគ្នានឹងជនត្រូវចោទដែរ[13]។ ការតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្មនៅក្រោមសម្បថ នៅពេលធ្វើការផ្តល់ភ័ស្តុតាង នោះគឺជាការកែប្រែដ៏ធំមួយទៅលើវិធានផ្ទៃក្នុង[14]។

៩- អង្គជំនុំជម្រះសាលាដំបូង បានលើកឡើងនូវញត្តិរបស់ អៀង សារី នៅក្នុងកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ ដោយបានថ្លែងថា៖ "ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជ្រើសរើស ដើម្បីធ្វើជាសាក្សី ហើយដែលត្រូវធ្វើសម្បថនោះ បញ្ហានីតិវិធីមិនចោទជាបញ្ហាឡើយ។ វិធាន២៤ និងវិធាន៣១ នៃវិធានផ្ទៃក្នុង បានគូសបញ្ជាក់រួចហើយអំពីបុគ្គលណាខ្លះដែលត្រូវធ្វើសម្បថ

---

[8] **E188** *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌទី ៥៣។

[9] **E188** *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌទី ៥២-៥៥។

[10] **E57** សំណើរបស់ អៀង សារី ស្នើឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថ ប្រសិនបើត្រូវបានអនុញ្ញាតឲ្យផ្តល់សក្ខីកម្មអំពីអ្វីដែលពួកគាត់បានដឹងពីរឿងក្តីព្រហ្មទណ្ឌ, ២៤ កុម្ភៈ ២០១១។

[11] **E57** *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌទី ៦, ៩។

[12] **E57** *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌទី ១១។

[13] **E57/1** សេចក្តីសង្កេតរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើញត្តិរបស់លោក អៀង សារី សុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថមុនពេលធ្វើសក្ខីកម្ម, ១៧ មីនា ២០១១, កថាខណ្ឌទី ២១។

[14] **E57/1** *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌទី ៥។

ស្របតាមបទដ្ឋានរបស់ អ.វ.ត.ក នោះ”[15]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ពីសេចក្ដីសម្រេចដោយផ្ទាល់មាត់នេះនៅក្នុងអនុស្សរណៈមួយ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១[16]។ នៅក្នុងសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អះអាងថា ដើមបណ្ដឹងរដ្ឋប្បវេណីមិនចាំបាច់ផ្ដល់សក្ខីកម្មនៅក្រោមសម្បថទេ ដើម្បីឲ្យអង្គជំនុំជម្រះធ្វើការពិចារណាលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី យកមកធ្វើជាភស្តុតាង។ ដូចជាភស្តុតាងនានាដែរ គេត្រូវតែធ្វើការពិចារណាលើសក្ខីកម្មដែលធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី ដោយនៅក្រោមបទដ្ឋានតែមួយដូចគ្នានឹងគ្រប់ភស្តុតាងដទៃទៀតដែលអង្គជំនុំជម្រះបានស្ដាប់ដូច្នោះដែរ។

១០- ដូចដែលបានកត់សម្គាល់នៅខាងលើ កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ មេធាវីការពារក្ដី អៀង សារី សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងលោកស្រីចៅក្រម Cartwright បានធ្វើការពិនិត្យមើលពីបញ្ហានេះជាថ្មីម្ដងទៀត[17]។

## III. សេចក្ដីសន្និដ្ឋាន

### ក. ប្រភពនៃវិធានស្ដីពីដើមបណ្ដឹងរដ្ឋប្បវេណីមិនផ្ដល់សក្ខីកម្មក្រោមសម្បថទេ

១១- ប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជា យកលំនាំតាមប្រព័ន្ធច្បាប់ស៊ីវិលនៅប្រទេសបារាំង។ តាមប្រពៃណីច្បាប់បារាំង គេមិនតម្រូវឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ជនជាប់ចោទ និងសមាជិកគ្រួសារជិតដិតរបស់ជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ផ្ដល់សក្ខីកម្មនៅក្រោមសម្បថទេ[18]។ វិធាននេះមានមូលដ្ឋាននៅលើទស្សនៈមួយដែលថា ពុំមានបុគ្គលណាម្នាក់អាចធ្វើជាសាក្សីផង និងជាភាគីផង នៅក្នុងកិច្ចដំណើរការនីតិវិធីតែមួយបាននោះឡើយ[19]។ ប្រភពនៃវិធាននេះ ទំនងជាមានមូលដ្ឋាននៅលើការយល់ឃើញថាជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីមានផលប្រយោជន៍

---

[15] **E1/2.1** ប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ, ៥ មេសា ២០១១, ទំព័រទី ១០០, បន្ទាត់ទី ៨-១៣ ។

[16] **E74** ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១, ៨ មេសា ២០១១, ទំព័រទី ១។

[17] ពង្រាងប្រតិចារឹក, ២៤ មករា ២០១៣, កថាខណ្ឌទី ៦២, ៧០-៧៥។

[18] ក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសបារាំង (បានបកប្រែជាភាសាអង់គ្លេសដោយ LegiFrance) បានធ្វើបច្ចុប្បន្នភាពកាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៦, មាត្រា ៣៣៥-៣៣៦។ សូមអានផងដែរ មាត្រាស្រដៀងគ្នានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ការបកប្រែខ្មែរ-អង់គ្លេស ឆ្នាំ២០០៨), មាត្រា១៥៦ (សាក្សីមិនស្បថ), ៣១២ (វិសមិតភាពរវាងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី និងឋានៈជាសាក្សី), ៣២៦ (ការស្ដាប់ចម្លើយរបស់ភាគី), ៣២៧ (ការជំទាស់ទៅនឹងការស្ដាប់ចម្លើយរបស់សាក្សី)។

[19] ព្រហ្មទណ្ឌ, ២៨ មករា ១៩៥៨, ព្រឹត្តិបត្រព្រហ្មទណ្ឌ, ៩១, បានលើកឡើងនៅក្នុង Jean-Francois, Renucci, *ក្រមនីតិវិធីព្រហ្មទណ្ឌ* (២០០៧), ទំព័រទី ៦៤០។

មួយនៅក្នុងលទ្ធផលនៃករណីរឿងក្តីនោះ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនមានភាពអនាគតិទេ។ នៅប្រទេសបារាំង ដើមបណ្តឹងរដ្ឋប្បវេណីមានសក្ខានុពលក្នុងការទទួលបាននូវសំណងជាប្រាក់ ដែលជាផ្នែកមួយនៃកិច្ចដំណើរការនីតិវិធីបែបដូច្នោះ។

១២- យុត្តិកម្មសម្រាប់វិធាននេះ គឺអនុវត្តបានតិចតួចនៅក្នុងស្ថានភាពនៃ អ.វ.ត.ក ខណៈដែលអង្គជំនុំជម្រះកំពុងចាត់ការបទចោទនានាអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ដែលបានកើតឡើងក្នុងកម្រិតធំធេង ដែលនៅក្នុងនោះ គេអាចនឹងមើលឃើញថាប្រជាជនទាំងអស់ដែលនៅរស់រានមានជីវិត គឺសុទ្ធតែជាជនរងគ្រោះផង និងជាសាក្សីសក្ខានុពលផង។ ទស្សនៈស្តីពីភាពជាជនរងគ្រោះ និងភាពលំអៀង គឺផ្សេងពីគ្នានៅក្នុងបរិបទនេះ។ បន្ថែមលើនេះ ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក មិនមាន សិទ្ធិទទួលបានសំណងជាប្រាក់តាមបុគ្គលនោះឡើយ ផ្ទុយទៅវិញ ត្រូវបានកម្រិតនៅត្រឹមសំណងជាសមូហភាព និងសំណងផ្លូវចិត្តទៅវិញ[20]។ ទិដ្ឋភាពនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក បានកម្រិតផងដែរនូវសនិទានភាព សម្រាប់ការធ្វើឲ្យមានភាពខុសគ្នាជាសំខាន់រវាងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។

១៣- ទោះបីជាតាមវិធាន ដើមបណ្តឹងរដ្ឋប្បវេណីមិនធ្វើសម្បថពេលផ្តល់សក្ខីកម្មក៏ដោយ ក៏តុលាការបារាំងនៅតែវាយតម្លៃលើសក្ខីកម្មជាភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងវាយតម្លៃអំពីទម្ងន់ និងតម្លៃជាភស្តុតាងនៃកំណាត់ហេតុស្តាប់ចម្លើយដែរ បន្ទាប់ពីភស្តុតាងទាំងអស់ត្រូវបានធ្វើសវនាការរួច ដោយផ្អែកទៅលើគោលការណ៍នៃសេរីភាពក្នុងការបង្ហាញសក្ខីកម្ម និងភស្តុតាង[21]។ ដោយអនុលោមតាមគោលការណ៍នេះ ចៅក្រមមិនត្រូវបានកំហិតត្រឹមមធ្យោបាយផ្តល់ភស្តុតាងជាក់លាក់ណាមួយឡើយ[22] ប៉ុន្តែផ្ទុយទៅវិញ ចៅក្រមពឹងផ្អែកលើការពិភាក្សារបស់ខ្លួនទៅលើភស្តុតាងទាំងឡាយដែលបានដាក់

---

[20] វិធាន២៣(១)(ខ) និង២៣*ស្ទួនបួន*នៃវិធានផ្ទៃក្នុង ("ផលប្រយោជន៍ទាំងនេះមិនត្រូវមានទម្រង់នៃសំណងជាប្រាក់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ")។

[21] ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង (បកប្រែជាភាសាអង់គ្លេសដោយ LegiFrance) ដែលបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី១ មករា ២00៦, មាត្រា៤២៧។ ទោះបីជាមាត្រា ៤២៧ ពាក់ព័ន្ធនឹងនីតិវិធី "កែប្រែ" (នីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌ) ក៏ដោយ ក៏មាត្រានេះត្រូវបានទទួលស្គាល់ជាឯកច្ឆន្ទថាជាមាត្រាដែលអាចអនុវត្តបាននៅចំពោះមុខយុត្តាធិការនៃសេចក្តីបង្គាប់ និងសាលក្រមទាំងអស់ សូម្បីតែនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ដែលដឹកនាំកិច្ចស៊ើបសួរ។ សូមមើល Jean Pradel, *Manuel de Procédure Pénale* (២00៦) ត្រង់ 364-365។ សូមមើលផងដែរ Crim. 13 janvier 1970, B.C., num. 21 និង Crim., 1er decembre 1990, B.C., num. 289, ដែលបានលើកយោងនៅក្នុង Jean Pradel, *Manuel de Procédure pénale* (២00៦), ទំព័រ 364-365។

[22] Crim., 24 Janvier 1973, B.C., num. 23 and 34, cited in Jean Pradel, *Manuel de Procédure pénale* (២00៦), ទំព័រ 786។ សូមមើលផងដែរ Corinne Renault-Brahinskym *Procédure Pénale* (២00៧) ទំព័រ 106-108។

នៅពេលដំណើរការនីតិវិធី[23]។ អាស្រ័យហេតុនេះ "ភ័ស្តុតាងទាំងអស់សុទ្ធតែអាចទទួលយកបាន"[24] រួមទាំង កំណត់ហេតុស្តាប់ចម្លើយដែលបានធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ឬជនជាប់ចោទ។ តាមគោលការណ៍នៃការវាយតម្លៃភ័ស្តុតាងដោយសេរី "បទល្មើសអាចត្រូវបានបង្ហាញតាមទម្រង់ណាមួយនៃភ័ស្តុតាង ហើយចៅក្រមធ្វើការសម្រេចសេចក្តីស្របតាមការជឿជាក់បំផុតក្នុងចិត្តរបស់ខ្លួន"[25]។ នៅចុងក្រោយនៃការជំនុំជម្រះ ចៅក្រមពិចារណាលើគ្រប់ភ័ស្តុតាងដោយសេរីដើម្បីវាយតម្លៃ ថាតើចៅក្រម "មានការជឿជាក់ក្នុងចិត្តរបស់ខ្លួន" ឬទេ[26]។ ហេតុដូច្នេះ ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីមិនស្បថក៏ដោយ សក្ខីកម្មរបស់គេមិនត្រូវបានពិចារណាថា មានតម្លៃទាបជាងក្នុងប្រព័ន្ធច្បាប់ស៊ីវិលបារាំងទេ។

## ខ. ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិផ្តល់ភ័ស្តុតាង

១៤- តាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក[27]។ វិធាន២៣(១) នៃវិធានផ្ទៃក្នុង ចែងថាៈ "ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងជនទាំងឡាយ

[23] ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង (បកប្រែជាភាសាអង់គ្លេសដោយ LegiFrance) ដែលបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី១ មករា ២០០៦, មាត្រា៤២៨។

[24] Jean Pradel, *Manuel de Procédure Pénale* (២០០៦), ទំព័រ 364។

[25] ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង (បកប្រែជាភាសាអង់គ្លេសដោយ LegiFrance) ដែលបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី១ មករា ២០០៦, មាត្រា៤២៧។

[26] ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង (បកប្រែជាភាសាអង់គ្លេសដោយ LegiFrance) ដែលបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី១ មករា ២០០៦, មាត្រា៣៥៣ៈ "នៅមុនចូលនិវត្តន៍ ប្រធានចៅក្រមអានសេចក្តីណែនាំដូចតទៅនេះ ដែលប្រភេទនៃសេចក្តីណែនាំទាំងនោះមួយចំនួនធំ ត្រូវបានជ្រើសយកដាក់នៅក្នុងផ្នែកដែលគេអាចមើលឃើញយ៉ាងច្បាស់បំផុតនៃការពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះយ៉ាងដូច្នេះថាៈ "ច្បាប់មិនសុំឱ្យចៅក្រមរិះរកមធ្យោបាយនានាដើម្បីឱ្យពួកគាត់ជឿជាក់នោះឡើយ, ច្បាប់មិនដាក់បន្ទុកពួកគាត់ឱ្យអនុវត្តតាមវិធានណាមួយដែលពួកគាត់ត្រូវតែទាញយកជាពិសេសចំពោះភាពពេញលេញ និងភាពគ្រប់គ្រាន់នៃភ័ស្តុតាងឡើយ។ ច្បាប់តម្រូវឱ្យពួកគាត់សួរខ្លួនឯងដោយស្ងៀមស្ងាត់ និងដោយមានការផ្ចុះបញ្ចាំង ព្រមទាំងស្វែងរកភាពស្មោះត្រង់ចំពោះសម្បជញ្ញៈរបស់ខ្លួនចំពោះអ្វីដែលជាចំណាប់អារម្មណ៍ដែលបានធ្វើនៅលើសំអាងហេតុរបស់ពួកគាត់តាមរយៈភ័ស្តុតាងដាក់បន្ទុកលើជនជាប់ចោទ និងអំណះអំណាងផ្សេងៗនៃការការពារខ្លួនគាត់។ ច្បាប់សុំឱ្យចៅក្រមតែមួយសំណួរនេះគត់ ដែលសំណួរនេះហ៊ុំព័ទ្ធនូវវិសាលដ៏ភាពពេញលេញចំពោះកាតព្វកិច្ចរបស់ពួកគាត់ៈ តើលោកជឿទេនៅក្នុងចិត្តរបស់អស់លោក"? សូមមើល Crim., 3 janvier 1978, arret num.2 ដូចបានលើកយោងនៅក្នុង Jean Pradel, *Manuel de Procédure Pénale* (២០០៦) ទំព័រទី 786។

[27] មាត្រា១៣នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា("បណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស")។វិធាន២៣(១) នៃវិធានផ្ទៃក្នុង។

ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រការចោទប្រកាន់”[28]។

១៥- សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ រួមទាំងសិទ្ធិបង្ហាញភស្តុតាង។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីថា “ក្នុងអំឡុងពេលសវនាការមានសិទ្ធិជួយអយ្យការក្នុងការបង្ហាញការពិត”[29]។ វិធាន១២*ស្ទួន២(៦)* អនុញ្ញាតឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្តល់ការគាំទ្រ រួមទាំង “ការស្តាប់ចម្លើយកូនក្តីរបស់ខ្លួន និងសាក្សី”[30]។ សិទ្ធិរបស់ជនរងគ្រោះ (និងបើដូច្នេះជាសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី) នឹងត្រូវបានតុលាការស្តាប់សវនាការ ត្រូវបានទទួលស្គាល់ផងដែរតាមរយៈសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការបំពានអំណាច”[31]។ ស្រដៀងគ្នានេះ តាមច្បាប់របស់សហភាពអឺរ៉ុប រដ្ឋជាសមាជិកត្រូវ “ធានាថាជនរងគ្រោះអាចត្រូវបានស្តាប់សវនាការនៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ និងអាចផ្តល់ភស្តុតាង”។[32]

១៦- សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវតុលាការស្តាប់សវនាការ គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងសិទ្ធិរបស់ជនជាប់ចោទនៅក្នុងការផ្តល់សក្ខីកម្ម និងបង្ហាញភស្តុតាងក្នុងនាមខ្លួនផ្ទាល់។ សិទ្ធិនោះត្រូវបានការពារដោយច្បាប់អន្តរជាតិដែលជាផ្នែកមួយនៃសិទ្ធិដ៏សំខាន់ និងជាមូលដ្ឋានចំពោះការជំនុំជម្រះ

---

[28] វិធាន២៣(១) នៃវិធានផ្ទៃក្នុង។

[29] **E72/3** សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យចេញសេចក្តីសម្រេចអំពី សិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឲ្យផ្តល់សក្ខីកម្ម ទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ, ៩ តុលា ២០០៩, កថាខណ្ឌទី៤១។

[30] វិធាន១២*ស្ទួនពីរ*(៦) នៃវិធានផ្ទៃក្នុង។ តាមច្បាប់បារាំង ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលយក មានសិទ្ធិស្នើឲ្យចៅក្រមស៊ើបអង្កេត “ស្តាប់សវនាការ ឬស្តាប់ចម្លើយ”។ ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង (បកប្រែជាភាសាអង់គ្លេសដោយ LegiFrance) ដែលបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី១ មករា ២០០៦, មាត្រា៨២-១។

[31] សេចក្តីប្រកាសស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការបំពានអំណាចរបស់អង្គការសហប្រជាជាតិ, U.N. Doc A/RES/40/34 (២៩ វិច្ឆិកា ១៩៨៥) ត្រង់មាត្រា ៦(ខ) (“ការអនុញ្ញាតមតិ និងកង្វល់ផ្សេងៗរបស់ជនរងគ្រោះដើម្បីបង្ហាញ និងពិចារណានៅក្នុងដំណាក់កាលសមស្របនៃកិច្ចដំណើរការនីតិវិធីដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគាត់រងការប៉ះពាល់ ដោយពុំធ្វើឲ្យខូចដល់ផលប្រយោជន៍របស់ជនជាប់ចោទ និងដែលស្របទៅនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិដែលពាក់ព័ន្ធ”)។

[32] សារាចរណែនាំលេខ 20120/29/EU របស់សភាអឺរ៉ុប និងរបស់ក្រុមប្រឹក្សា ចុះថ្ងៃទី២៥ តុលា ២០១២ ដែលកំណត់បទដ្ឋានអប្បបរមាស្តីពីសិទ្ធិ ការគាំទ្រ និងការការពារជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការដាក់ជំនួសសេចក្តីសម្រេចស្តីពីក្របខណ្ឌក្រុមប្រឹក្សាលេខ 2001/220/JHA, ទនានុប្បវត្តិផ្លូវការរបស់សហភាពអឺរ៉ុបលេខ L 315/57 (១៤ វិច្ឆិកា ២០១២) ត្រង់មាត្រា១០(១)។

ដោយត្រឹមត្រូវយុត្តិធម៌[33]។ សិទ្ធិនេះក៏ត្រូវបានការពារយ៉ាងពិសេស នៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលធានាចំពោះសិទ្ធិរបស់ជនជាប់ចោទក្នុងការ "ទទួលបាននូវការបង្ហាញ និងការដេញដោលភ័ស្តុតាងក្នុងនាមខ្លួនផ្ទាល់ ក្នុងលក្ខខណ្ឌដូចគ្នានឹងភ័ស្តុតាងដាក់បន្ទុកដែរ"[34]។

១៧- ដូចជនជាប់ចោទដែរ ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីនៃកិច្ចដំណើរការនីតិវិធីទាំងនេះ ហើយអាចជាការរំលោភលើសិទ្ធិរបស់ខ្លួន ក្នុងការចូលរួម និងផ្តល់ភ័ស្តុតាង ប្រសិនបើទម្ងន់ ឬតម្លៃភ័ស្តុតាងនៃសក្ខីកម្មរបស់ខ្លួនត្រូវបានសន្មតជាស្វ័យប្រវត្តិថា មានតម្លៃទាបជាង ដោយសារតែខ្លួនមិនបានស្បថពេលផ្តល់សក្ខីកម្ម។

## គ. ទម្ងន់ត្រូវបានផ្តល់ចំពោះសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី គួរត្រូវបានកំណត់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចគ្នានឹងសក្ខីកម្មរបស់សាក្សី

១៨- នៅចុងក្រោយ ការទទួលខុសត្រូវរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីវាយតម្លៃពីទម្ងន់ និងតម្លៃជាភ័ស្តុតាងចំពោះភ័ស្តុតាងដែលបានបង្ហាញនៅចំពោះមុខខ្លួន[35]។ តាមគោលការណ៍នៃការវាយតម្លៃ

---

[33] សេចក្តីសម្រេចចិត្តរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិលេខ 217A(III), *សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស*, អនុម័ត ថ្ងៃទី ១០ ធ្នូ ១៩៤៨, មាត្រា១១(១)។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ១៦ ធ្នូ ១៩៦៦, 999 U.N.T.S. 171, មាត្រា ១៤(៣)(ង) "ដើម្បីដេញដោល ឬឱ្យគេដេញដោលចំពោះសាក្សីប្រឆាំងខ្លួនគាត់ និងដើម្បីទទួលបានការចូលរួម និងការដេញដោលសាក្សីក្នុងនាមខ្លួនគាត់ តាមលក្ខខណ្ឌដូចគ្នានឹងសាក្សីប្រឆាំងខ្លួនគាត់ដែរ")។ អនុសញ្ញាសម្រាប់ការការពារសិទ្ធិមនុស្ស និងសិទ្ធិសេរីភាពជាមូលដ្ឋាន "អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស") 213 U.N.T.S. 221, ៤ វិច្ឆិកា ១៩៥០, មាត្រា៦(៣)(ឃ)។ អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស, ២១ វិច្ឆិកា ១៩៦៩, 1144 U.N.T.S. 143, មាត្រា៨(២)(ឆ) ("សិទ្ធិការពារខ្លួនដើម្បីដេញដោលសាក្សីដែលមានវត្តមាននៅក្នុងសវនាការ និងក្នុងនាមជាសាក្សី ដើម្បីទទួលបានការចូលបង្ហាញខ្លួនរបស់អ្នកជំនាញ ឬបុគ្គលដទៃទៀតដែលអាចបង្ហាញអង្គហេតុបាន")។

[34] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានការដាក់បញ្ចូលវិសោធនកម្មដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤, មាត្រា៣៥*ថ្មី*(ង)។

[35] **E188** សាលក្រម, ២៦ កក្កដា ២០១០, កថាខណ្ឌទី៤២។ *សូមមើលផងដែរ* **E43/4** សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភ័ស្តុតាង, ២៦ ឧសភា ២០០៩ ត្រង់កថាខណ្ឌទី៧ ("នៅពេលដាក់នៅចំពោះមុខអង្គជំនុំជម្រះ តម្លៃដាក់បន្ទុកនៃភ័ស្តុតាងនេះ និងការថ្លឹងថ្លែងឱ្យមានការយល់ស្របទៅនឹងភ័ស្តុតាងនោះ នឹងត្រូវបានធ្វើការវាយតម្លៃដោយអង្គជំនុំជម្រះ")។ **E176** សេចក្តីសម្រេចលើសំណើរបស់ភាគីនានាសុំដាក់សម្ភារៈមួយចំនួននៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង៨៧(២), ២៨ តុលា ២០០៩ ត្រង់កថាខណ្ឌទី៣ ("នៅពេលដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះត្រូវធ្វើការវាយតម្លៃអំពីតម្លៃជាភ័ស្តុតាងពីក្នុងចំណោមភ័ស្តុតាងទាំងអស់នោះ និងថ្លឹងថ្លែងសម្រេចដើម្បីឱ្យស្របជាមួយនឹងការវាយតម្លៃនោះ")។ **E96/7** សេចក្តីសម្រេចលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ទាក់ទងនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ២០ មិថុនា ២០១២, ត្រង់ទំព័រ១៨ ("ប្រកាសថា លក្ខណៈវិនិច្ឆ័យគូសបញ្ជាក់ក្នុងវាក្យខណ្ឌ៤(២) និង៤(៣) នៃសេចក្តីសម្រេចនេះ ត្រូវបានអង្គជំនុំជម្រះយកទៅពិចារណាជាបន្តទៀតនៅពេលធ្វើការវាយតម្លៃអំពីតម្លៃជាភ័ស្តុតាង និងការថ្លឹងថ្លែងឱ្យមាន

ភស្តុតាងដោយសេរី តម្លៃជាភស្តុតាង និងការថ្លឹងថ្លែងឲ្យមានការទទួលយកទៅជាភស្តុតាងនោះ គឺជាការស្រាវជ្រាវមួយដែលកើតឡើងនៅពេលដែលភស្តុតាងទាំងអស់ ត្រូវបានទទួលយកទៅក្នុងសំណុំរឿង។ ការស្រាវជ្រាវនេះកើតឡើងដោយមានគោលបំណងកំណត់ថាតើ ភស្តុតាងដែលទទួលយកទំនងបង្ហាញ ឬមិនបង្ហាញការចោទប្រកាន់ក្នុងរឿងក្តីនោះ។

១៩- តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀតបានបញ្ជាក់អះអាងដូច្នេះថា តម្លៃជាភស្តុតាងត្រូវបានវាយតម្លៃបន្ទាប់ពីភស្តុតាងទាំងអស់ត្រូវបានធ្វើសវនាការរួច។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY បានថ្លែងថា ភស្តុតាងគួរត្រូវបានវាយតម្លៃ “ទៅតាមបរិបទនៃកំណត់ហេតុសវនាការទាំងមូល”[36]។ ស្រដៀងគ្នានេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR បានថ្លែងថា “ការវាយតម្លៃទម្ងន់នៃភស្តុតាងដែលមាននៅក្នុងភស្តុតាងនោះ គឺជាការវាយតម្លៃមួយដែលនឹងត្រូវធ្វើឡើងដោយអង្គជំនុំជម្រះនៅចុងក្រោយនៃរឿងក្តី”[37]។

២០- ប្រព័ន្ធច្បាប់របស់បារាំងក៏តម្រូវឲ្យមានការវាយតម្លៃអំពីតម្លៃភរនីយភាពនៃភស្តុតាងដែរ នៅចុងបញ្ចប់នៃសវនាការ។ គោលការណ៍ស្តីពីការវាយតម្លៃភស្តុតាងដោយសេរី និងសញ្ញាណក្នុងការដាក់ទោស តម្រូវ

---

ការយល់ស្របទៅនឹងភស្តុតាងដែលបានដាក់នៅចំពោះអង្គជំនុំជម្រះ បន្ទាប់ពីសេចក្តីសម្រេចនេះ”)។ **E1/51.1** ប្រតិចារឹក, ២០ មីនា ២០១២ ត្រង់ទំព័រ៥៣ បន្ទាត់២១-២២ (“ហើយនៅក្នុងការពិចារណា និងវាយតម្លៃលើទម្ងន់សក្ខីកម្មរបស់សាក្សីណាម្នាក់ វាជាឆន្ទានុសិទ្ធិផ្តាច់មុខរបស់អង្គជំនុំជម្រះ”)។ **E1/134** ប្រតិចារឹក, ១៨ តុលា ២០១២ ត្រង់ទំព័រ៩០ បន្ទាត់១៩-២៤ (“យ៉ាងណាមិញ អង្គជំនុំជម្រះសូមរំលឹកឡើងវិញថា តម្លៃជាភស្តុតាងនៃមតិយោបល់ដែលបានធ្វើឡើងដោយជនជាប់ចោទណាម្នាក់ ដូចក្នុងករណីដែលភស្តុតាងទាំងអស់បានបង្ហាញនៅក្នុងការជំនុំជម្រះនេះនឹងត្រូវធ្វើការវាយតម្លៃស្របទៅតាមវិធានផ្ទៃក្នុង។ នៅពេលដែលអង្គជំនុំជម្រះចេញសាលក្រមសម្រេចសេចក្តីរបស់ខ្លួន គឺសាលក្រមដែលនឹងចេញទាក់ទងនឹងបញ្ហានេះ គឺនឹងមានសំអាងហេតុ”)។

[36] *រដ្ឋអាជ្ញា ទល់នឹង Milan Martić*, សំណុំរឿងលេខ: IT-95-11-T, សាលក្រមរបស់អង្គជំនុំជម្រះ (អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY), ១២ មិថុនា ២០០៧, ត្រង់កថាខណ្ឌទី៣០ (លើកយោង *រដ្ឋអាជ្ញា ទល់នឹង Milan Martić*, សំណុំរឿងលេខ: IT-95-11-T, សេចក្តីសម្រេចស្តីពីការអនុម័តគោលការណ៍ណែនាំស្តីពីបទដ្ឋានសម្រាប់គ្រប់គ្រងការទទួលយកភស្តុតាង (អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY), ១៩ មករា ២០០៦, ត្រង់កថាខណ្ឌទី៦។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Vujadin Popović និងគូកន*, សំណុំរឿងលេខ: IT-05-88, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃការប្រាស្រ័យទំនាក់ទំនងដែលស្ទាក់ចាប់បាន (អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ ICTY), ៧ ធ្នូ ២០០៧, ត្រង់កថាខណ្ឌទី៣៦ (“ប្រសិនបើឯកសារមួយត្រូវបានទទួលយក ការវាយតម្លៃលើខ្លឹមសាររបស់ឯកសារទាំងនោះដើម្បីថ្លឹងថ្លែងពីទម្ងន់របស់វាឲ្យបានសមស្រប គឺជាការងារមួយសម្រាប់ថ្ងៃក្រោយ, ដែលបានអនុវត្ត... ទៅតាមបរិបទទាំងស្រុងនៃកំណត់ហេតុភស្តុតាងដែលបានបង្កើតឡើងដោយភាគីនានា”)។

[37] *រដ្ឋអាជ្ញា ទល់នឹង Pauline Nyiramasuhuko*, សំណុំរឿងលេខ: ICTR-98-42-AR73.2, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Pauline Nyiramashuko ស្តីពីភាពអាចទទួលយកបាននៃភស្តុតាង (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR), ៤ តុលា ២០០៤ ត្រង់កថាខណ្ឌទី៦។

ឲ្យចៅក្រមជំនុំជម្រះធ្វើការវាយតម្លៃលើភស្តុតាងដោយឯករាជ្យ ដើម្បីឈានទៅធ្វើសេចក្តីសម្រេច[38]។ ទោះបីជាសក្ខីកម្មត្រូវបានធ្វើឡើងដោយមាន ឬមិនមានការធ្វើសម្បថក៏ដោយក៏វាមិនមែនជាកាតព្វកិច្ច ដែលចងចៅក្រមជំនុំជម្រះក្នុងការសម្រេចទាំងឡាយ អំពីភាពគួរឲ្យជឿទុកចិត្តបាននៃសក្ខីកម្មនោះ។ ផ្ទុយទៅវិញ ចៅក្រមត្រូវតែវាយតម្លៃភស្តុតាងដោយសេរី។ ចៅក្រមជំនុំជម្រះគឺជាចៅក្រមដែលមាន បទពិសោធន៍ និងទទួលការបណ្តុះបណ្តាល ជាងអ្នកច្បាប់ធម្មតា និងត្រូវមានសមត្ថភាពក្នុងការវាយ តម្លៃភស្តុតាងដោយឯករាជ្យ។

២១- នៅពេលវាយតម្លៃលើភស្តុតាងនៅពេលបញ្ចប់សវនាការ អង្គជំនុំជម្រះសាលាដំបូងអាចពិនិត្យមើល ទៅលើសេចក្តីណែនាំអន្តរជាតិ ស្តីពីកត្តានានាដែលអាចត្រូវពិចារណានៅក្នុងការវាយតម្លៃទៅលើភាព គួរឲ្យជឿទុកចិត្តបាន និងថ្លឹងថ្លែងលើសក្ខីកម្មសាក្សី។ តុលាការ ICTY និង ICTR ក្នុងការវាយតម្លៃ អំពីភាពគួរឲ្យជឿទុកចិត្តនៃសក្ខីកម្មសាក្សី បានចាត់ទុកថាជាកត្តានូវ៖ អត្តចរិតរបស់សាក្សី[39], ភាព ស៊ីសង្វាក់គ្នានៃចម្លើយរបស់សាក្សី, និងថាតើភាពស៊ីសង្វាក់គ្នាណាមួយនោះ មានជាប់ទាក់ទងទៅនឹង អង្គហេតុជាក់ស្តែងដែរ ឬទេ[40], ថាតើសាក្សីមានហេតុផលលាក់កំបាំងក្នុងការផ្តល់សក្ខីកម្មរបស់ខ្លួន

---

[38] ក្រមនីតិព្រហ្មទណ្ឌបារាំង, អត្ថបទច្របាច់បញ្ចូលគ្នា ចុះថ្ងៃទី២៩ តុលា ២០១០, មាត្រា ៣៥៣។

[39] សូមអាន *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Mile Mrkšić និងគូគ្នាផ្សេងទៀត*, សំណុំរឿងលេខ IT-95-13/1-T, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY),ចុះថ្ងៃទី៥ ឧសភា ២00៩ ត្រង់កថាខណ្ឌទី៣0១ (" ដែលយល់ព្រមទៅតាម អ្នកដែលរកឃើញអង្គហេតុ គឺមានលក្ខណៈសមស្របជាពិសេស ដែលការជំទាស់នឹងអង្គហេតុទាក់ទងទៅនឹងបញ្ហាស្តីពីភាពគួរឲ្យជឿទុកចិត្តបាននៃចម្លើយសាក្សី។ អ្នកដែលរកឃើញអង្គហេតុ នៅក្នុងករណីនេះ អង្គជំនុំជម្រសាលាដំបូង ជាពិសេសគឺមានភាពស័ក្តិសមសម្រាប់ធ្វើការវាយតម្លៃទៅលើសំណួរប្រភេទនេះ ដោយសារខ្លួនបានមានឱកាសក្នុងការពិនិត្យទៅលើសកម្មភាពរបស់សាក្សី និងវាយតម្លៃលើភស្តុតាងរបស់គេដោយផ្ទាល់ នៅក្នុងបរិបទនៃកំណត់ត្រា នៃការជំនុំជម្រះក្តីទាំងមូល")។ ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង *George Rutaganda*, សំណុំរឿងលេខ ICTR-96-3-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី២៦ ឧសភា ២00៣ ត្រង់កថាខណ្ឌទី២១ (" អង្គជំនុំជម្រះសាលាដំបូងមានអត្ថប្រយោជន៍នៅក្នុងការសង្កេតមើលសាក្សីម្នាក់ៗដោយផ្ទាល់ និបានស្តាប់ចម្លើយរបស់ពួកគេនៅពេលដែលពួកគេផ្តល់សក្ខីកម្ម ហើយក៏ដូចជាការដាក់ឲ្យនៅត្រង់ទីកន្លែងដែលល្អប្រសើរជាងដើម្បីនឹងធ្វើការជ្រើសរើសរវាងការរៀបរាប់រឿងរ៉ាវនានាដែលបែកចេញពីគ្នាអំពីព្រឹត្តការណ៍ដូចគ្នាតែមួយ")។

[40] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Ramush Haradinaj*, សំណុំរឿងលេខ IT-04-84*bis*-T សាលក្រម ( អង្គជំនុំជម្រះសាលាដំបូងទីII នៃតុលាការ ICTY), ចុះថ្ងៃទី២៩ វិច្ឆិកា ឆ្នាំ២០១២ ត្រង់កថាខណ្ឌទី១៨០។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Zoran Kupreškić និងគូកនផ្សេងទៀត*, សំណុំរឿងលេខ IT-95-16-A, សាលដីកា ( អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី២៣ តុលា ២00១ ត្រង់កថាខណ្ឌទី៣១។ *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង* George Rutaganda, សំណុំរឿងលេខ ICTR-96-3-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR), ចុះថ្ងៃទិ២៦ ឧសភា ២00៣ ត្រង់កថាខណ្ឌទី១៧៨-១៨២, ១៨៥-១៨៦ (ដែលផ្តល់ការយល់ព្រម *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង* George Rutaganda, សំណុំរឿងលេខ ICTR-96-3-A, សាលក្រម ( អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTR), ចុះថ្ងៃទី ៦ ធ្នូ ១៩៩៩ ត្រង់កថាខណ្ឌទី១៩, ២៥១-២៥៣) ។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Eliézer*

ដែរ ឬទេ[41], និងទម្ងន់បន្ថែមនៃសក្ខីកម្មរបស់សាក្សី[42]។ សក្ខីកម្មនានារបស់ដើមបណ្ដឹងរដ្ឋប្បវេណី មិនគួរត្រូវបានចាត់ទុកថាមានតម្លៃទាបជាងឡើយ, ដោយគ្រាន់តែមកពីប្រការដែលថាសក្ខីកម្មទាំងនោះត្រូវបានធ្វើឡើងដោយមិនមានការធ្វើសម្បថនោះ។ ជាការល្អ អង្គជំនុំជម្រះសាលាដំបូងគួរតែពិចារណាលើកត្តាទាំងឡាយដូចដែលបានចែងខាងលើ ក្នុងចំណោមសញ្ញាបង្ហាញផ្សេងទៀតនៃភាពគួរឱ្យជឿទុកចិត្តបាននៅក្នុងការវាយតម្លៃអំពីទម្ងន់ និងតម្លៃភរនីយភាពចំពោះសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ក្នុងការធ្វើដូច្នេះ អង្គជំនុំជម្រះគួរយកចិត្តទុកដាក់ចំពោះប្រការដែលថា ដូចគ្នានឹងសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយដែលផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ គឺត្រូវតែបានដេញដោល(ហេតុដូចនេះ គឺការធ្វើតេស្ដលើភ័ស្ដុតាងរបស់ពួកគេ ) ដោយចៅក្រម សហព្រះរាជអាជ្ញា មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីការពារក្ដី។

២២-ផ្អែកលើមូលដ្ឋាននៃការវិភាគនេះ នៅទីបំផុត អង្គជំនុំជម្រះសាលាដំបូងអាចកំណត់ថាសក្ខីកម្មមួយចំនួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬជនជាប់ចោទជាពិសេស មានភាពលំអៀង ឬមួយមិនអាចឱ្យជឿទុកចិត្តបាន និងហេតុដូចនេះ គឺមិនអាចផ្ដល់នូវទម្ងន់ដែលគួរឱ្យកត់សម្គាល់ណាមួយ។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាជូនជាមតិថា ការកំណត់បែបនេះ ត្រូវតែធ្វើឡើងដោយផ្អែកទៅតាមកត្តាមួយករណីម្ដងៗ ហើយថា សក្ខីកម្មនៅក្នុងតុលាការដែលផ្ដល់ដោយដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទនានា គឺត្រូវបានធ្វើតេស្ដតាមរយៈការដេញដោលដោយចៅក្រម និងមេធាវី ដែលមិនអាចចាត់ទុកថាមានទម្ងន់ទាបជាងបានទេ ព្រោះដោយសារតែសក្ខីកម្មទាំងនេះត្រូវបានធ្វើឡើងដោយមិនធ្វើសម្បថ។

---

*Niyitegeka*, សំណុំរឿងលេខ ICTR 96-14-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR), ចុះថ្ងៃទី៩ កក្កដា ២00៤ ត្រង់កថាខណ្ឌពីទី ៩៥-៩៦។

[41] សូមអាន *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Mile Mrkšić និងគូកនផ្សេងទៀត*, សំណុំរឿងលេខ IT-95-13/1-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូងទីII នៃតុលាការ ICTY),ចុះថ្ងៃទី២៧ កញ្ញា ២00៧ ត្រង់កថាខណ្ឌទី៣00 (“ អង្គជំនុំជម្រះ ក៏មិនអាចទទួលយល់ព្រមបានដែរនូវភ័ស្ដុតាងរបស់គាត់ទាក់ទងនៅក្នុងរឿងនេះ, ចាប់តាំងពីការវាយតម្លៃរបស់ខ្លួនលើភាពគួរឱ្យជឿទុកចិត្តបានរបស់គាត់ ដោយសារវាហាក់ដូចជាមានបំណងចង់ជៀសវាងពីការធ្វើសេចក្ដីសន្និដ្ឋានថា Karanfilov បានដឹងអំពីបញ្ហាសន្តិសុខរបស់ពួកអ្នកទោសនៅក្នុងបន្ទាយ។”) ។ *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Ramush Haradinaj* , សំណុំរឿងលេខ IT-04-84 ស្ទួន, សាលក្រម (អង្គជំនុំជម្រះសាលាដំបូងទីII នៃតុលាការ ICTY),ចុះថ្ងៃទី២៩ វិច្ឆិកា ២០១២ ត្រង់កថាខណ្ឌទី១៨0។ *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Eliézer Niyitegeka*, សំណុំរឿងលេខ ICTR 96-14-A, សាលដីកា ( អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី៩ កក្កដា ២00៤ ត្រង់កថាខណ្ឌទី៩៨។

[42] *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Zoran Kupreškić និងគូកនផ្សេងទៀត*, សំណុំរឿងលេខ IT-95-16-A, សាលដីកា ( អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី២៣ តុលា ២00១ ត្រង់កថាខណ្ឌទី២២0។ *ករណីរឿងក្ដីរបស់រដ្ឋអាជ្ញា ទល់នឹង George Rutaganda*, សំណុំរឿងលេខ ICTR-96-3-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR), ចុះថ្ងៃទី២៣ ឧសភា ២00៣ ត្រង់កថាខណ្ឌទី២៧-២៩។

## IV. សេចក្តីសន្និដ្ឋាន

២៣-អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាស្នើដោយគោរព សុំឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាធ្វើការពិចារណាលើសេចក្តីសង្កេតនេះ និងធ្វើការថ្លឹងថ្លែងលើទម្ងន់ និងតម្លៃភរទីភាពនៃសក្ខីកម្មដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ ស្របទៅតាមបទដ្ឋានដូចគ្នាដែលបានប្រើសម្រាប់សក្ខីកម្មរបស់សាក្សីដែរ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |